ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការក្រុងភ្នំពេញ**

សាលក្រមព្រហ្មទណ្ឌ

លេខ ៣៧ "ខ" ចុះថ្ងៃទី ១៦

ខែ មិថុនា ឆ្នាំ ២០០៣

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៥០១ ចុះថ្ងៃទី ១៦

ខែ កញ្ញា ឆ្នាំ ២០០២

សាលក្រមនេះបានចូលជាស្ថាពរពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ នេះតទៅ

ដោយគ្មានភាគីណាមួយប្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលច្បាប់ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៣

ក្រឡាបញ្ជី

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការក្រុងភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងភ្នំពេញ នាថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការក្រុងភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងភ្នំពេញ

**មេធាវី**

លោក [redacted] មេធាវីការពារជនជាប់ចោទ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ ១៥០១ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០២ ដែលមានជនជាប់ចោទ :

-ឈ្មោះ ត សតត ហៅ តី ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអព្ទេង ស្រុកដង្កោ ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិសន្សំកុសល ១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ របររកស៊ីកម្មករឆ្នោត នៅលីវ ឪពុកឈ្មោះ ត ខ (ស) ម្តាយឈ្មោះ ណ ម (រ) ទោសពីមុន *គ្មាន* ។

-ឈ្មោះ អ គន ហៅ ប្រុស ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្អិរ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិព្រៃកទាល់ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ របររកស៊ីនៅផ្ទះ នៅលីវ ឪពុកឈ្មោះ អ មល (រ) ម្តាយឈ្មោះ ស សះ (រ) ទោសពីមុនគ្មាន ។

-ឈ្មោះ ឆ គស ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ កើតនៅខេត្តបាត់ដំបង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិសន្សំកុសល ១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ របររកស៊ីនៅផ្ទះ នៅលីវ ឪពុកឈ្មោះ គ ស (រ) ម្តាយឈ្មោះ ន ឈល (រ) ទោសពីមុន *គ្មាន*។

ត្រូវជាប់ចោទពីបទ : "ប្លន់ទ្រព្យសម្បត្តិប្រជាជន" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ ។

អយ្យការអមតុលាការក្រុងភ្នំពេញ បានធ្វើដីកាសន្និដ្ឋានស្ថាពរលេខ ៧៩៩ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៣ ចោទប្រកាន់លើឈ្មោះ ក សគគ ហៅ គី ភេទប្រុស អាយុ ២២ឆ្នាំ. ឈ្មោះ អ គន ហៅ ឬស ភេទប្រុស អាយុ ២០ឆ្នាំ និងឈ្មោះ គ ភស ភេទប្រុស អាយុ ១៩ឆ្នាំ ពីបទប្លន់ទ្រព្យសម្បត្តិប្រជាជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

**នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ ក សគគ ឆ្លើយថា កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោង ៥:០០ ល្ងាច ខ្ញុំបាទបានយកក្រដាសចេញឆ្នោតទៅឱ្យកូនកញ្ចែងកត់ឆ្នោតចំនួន ០៥កន្លែង ។ កន្លែងចុងក្រោយគេនៅវេលាម៉ោង ០៥ និង ២០នាទីល្ងាច ដល់តូបយាយ ខ កែងវត្តទួលទំពូង ។ ពេលចេញពីកន្លែងឆ្នោតមក ខ្ញុំបានទិញទំប៉ុងនៅក្បែររបងពេទ្យផ្សារដើមថ្កូវ លុះចេញមកវិញដល់មុខផ្ទះយាយ ខ នៅវេលាម៉ោង ០៥ និង ៣០នាទី ពេលនោះឈ្មោះ ខ បានខ្ចីម៉ូតូខ្ញុំបាទអស់រយៈពេល ០៥នាទី ទើបយកម៉ូតូមកឱ្យខ្ញុំវិញ បន្ទាប់មកខ្ញុំបានជិះម៉ូតូទៅងូតទឹកនៅផ្ទះរបស់បងឈ្មោះ ក ចឋទ នៅពេលនោះឈ្មោះ ឃ បានសុំដោយសារទៅផ្ទះគេទៀតផង ហើយខ្ញុំងូតទឹកនៅផ្ទះរបស់បងអស់រយៈពេល ០៦ នាទី បន្ទាប់មកបងរបស់ខ្ញុំបានប្រើខ្ញុំយកកំប៉ុងហ្គាស់ទៅដូរ ពេលទៅដល់ផ្ទះអ្នកលក់ហ្គាស់នោះ ខ្ញុំបាទបានហុចកំប៉ុងហ្គាស់ឱ្យកូនអ្នកលក់ឈ្មោះ ឡ ពេលនោះឈ្មោះ ឡ មិនទាន់ហុចកំប៉ុងហ្គាស់ឱ្យខ្ញុំវិញផង ស្រាប់តែសមត្ថកិច្ចមកចាប់ខ្លួនខ្ញុំតែម្តង ។ ចំពោះពាក្យចោទប្រកាន់ខ្ញុំបាទថា នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោង ០៥ និង ៤៥ នាទីល្ងាច ចោទខ្ញុំបាទថា ខ្ញុំបាទបានចូលរួមប្លន់ម៉ូតូនោះ ខ្ញុំសុំបដិសេធចោលទាំងស្រុង ។

ជនជាប់ចោទឈ្មោះ អ គន ឆ្លើយថា កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោងជាង ០៥ល្ងាច ខ្ញុំបាទបានទៅអង្គុយលេងនៅសាលាចំរើនផល លើគ្រែក្រោមអំពិលផ្ទះជាមួយឈ្មោះ ក, ឈ, ព និង ត ឃ លុះវេលាម៉ោង ០៦ និង ៣០នាទីល្ងាច ទើបខ្ញុំត្រឡប់មកផ្ទះវិញ ។ ហើយប៉ូលីសចាប់ខ្លួនខ្ញុំបាទនៅនឹងផ្ទះ គឺថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោង ០៧ព្រឹក ក្នុងករណីដែលចោទប្រកាន់ថា ខ្ញុំបាទថា ខ្ញុំបានចូលរួមធ្វើសកម្មភាពប្លន់ម៉ូតូរបស់គេ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ នោះ ខ្ញុំបាទសុំបដិសេធទាំងស្រុង ពីព្រោះខ្ញុំបាទពុំបានធ្វើសកម្មភាពប្លន់ម៉ូតូរបស់គេទេ ។

ជនជាប់ចោទឈ្មោះ គ ភស ឆ្លើយថា កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោង ០៤ល្ងាច ខ្ញុំបាទបានចុះពីលើផ្ទះរបស់ខ្ញុំមក ហើយបានទៅលេងផ្ទះឈ្មោះ ញ ដែលមានទីលំនៅភូមិសន្សំកុសល ពេលមកដល់ក៏មានមិត្តភក្តិប្រហែល ០៨នាក់ គឺ ០៤នាក់ បានអង្គុយលេងបៀនៅក្រោមផ្ទះ មានឈ្មោះ ញ, ទ, ខ និង ឈ្មោះ ឃ ចំណែកអ្នកផ្សេងទៀតរួមទាំងខ្ញុំបាទបានឈរលេងនៅខាងមុខផ្ទះមានឈ្មោះ ស, ឃ, អ, អ និង រូបខ្ញុំ ដែលមានទីលំនៅភូមិសន្សំកុសលជាមួយគ្នា ។ ចំពោះការចោទប្រកាន់ខ្ញុំបាទថា បានចូលរួមធ្វើសកម្មភាពប្លន់ម៉ូតូ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោង ០៥ និង ៤៥នាទីនោះ ខ្ញុំសុំបដិសេធទាំងស្រុង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពទេ ។

ជនរងគ្រោះឈ្មោះ ច សធរ ( អវត្តមាន ) តាមកំណត់ហេតុថា កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោង ០៥ និង ៤៥នាទីល្ងាច នាងខ្ញុំបានជិះម៉ូតូម៉ាកសេ ១០០ ស៊េរី ២០០១ ពណ៌ខ្មៅ ជារបស់បងប្រុសខ្ញុំឈ្មោះ ណ មរឌ ពេលនាងខ្ញុំជិះម៉ូតូនេះចេញទៅមានបំណងទៅទិញទឹកកកនៅខាងជើងវត្តសន្សំកុសល ។ ពេលនាងខ្ញុំកំពុងធ្វើដំណើរលើផ្លូវក្រោយវត្តក៏មានម៉ូតូ ០១គ្រឿង ម៉ាកវីវា ពណ៌ស្រដៀងខ្មៅ នាងខ្ញុំមិនច្បាស់ ជិះគ្នា ០៣នាក់សុទ្ធតែប្រុស ពេលនោះវាបានជិះម៉ូតូរបស់វាវ៉ាខាងស្តាំដៃនាងខ្ញុំ ហើយបត់ចូលខាងឆ្វេងបន្តិចធ្វើឱ្យម៉ូតូនាងខ្ញុំទៅមុខមិនកើតរំពេច

រនោះអ្នកបើកម៉ូតូវីវ៉ា ដែលជិះគ្នា ០៣នាក់នោះ បានយកដៃឆ្វេងរបស់គេមកមួលហ្គែម៉ូតូនាងខ្ញុំមិនឱ្យរលត់ភ្លាមនោះអ្នកជិះក្រោយក៏ស្ទុះចុះពីលើម៉ូតូជើងម្ខាងមិនទាន់ផុតម៉ូតូផង ក៏ដកកាំភ្លើងមកភ្ជង់នាងខ្ញុំចំគុម្ពត្រចៀកខាងស្តាំឡើង ហើម និង ជាំ ។ ពេលពួកចោរភ្ជង់នាងខ្ញុំនោះអ្នកភ្ជង់បានស្រែកថា ឱ្យនាងខ្ញុំចុះពីម៉ូតូ ពេលនោះនាងខ្ញុំក៏ចុះពីលើម៉ូតូ ហើយរត់ចូលក្នុងរបងកុមារសង្គ្រោះកែងវត្តសន្សំកុសលខាងក្រោយ ពេលភ្ជង់នាងខ្ញុំនេះ អ្នកជិះកណ្តាលពុំមានធ្វើសកម្មភាពអ្វីទេ ម៉ូតូរបស់នាងខ្ញុំត្រូវបានអ្នកដែលភ្ជង់នាងខ្ញុំជិះយកទៅតាមផ្លូវខាងឆ្វេងវត្តសន្សំកុសល ឯបញ្ហាផ្សេងទៀតនាងខ្ញុំ ពុំបានដឹងទេ ព្រោះភ័យពេកក៏រត់មកផ្ទះប្រាប់បងរបស់ខ្ញុំតាមផ្លូវកាត់ចូលតាមក្រោយផ្ទះបងខ្ញុំក៏ឆោឡោក៏ស្វែងរកម៉ូតូ តែរកមិនឃើញទេ ក៏ទៅប្តឹងប៉ូលីសសង្កាត់បឹងទំពុនប្រហែលម៉ោង ០៦ជាង ការប្លន់នេះពុំមានបាញ់ទេ គឺវាភ្ជង់តែម្តង ។ នៅកន្លែងប្លន់មានមនុស្សជាច្រើន តែមានមនុស្សប្រុស ០២នាក់រត់មកពីទិសខាងត្បូងស្របទិសម៉ូតូវីវ៉ា ដែលប្លន់នាងខ្ញុំនោះ ពេលដែលពួកគេមកដល់គេសួរថា មានរឿងអ្វី នាងខ្ញុំថា គេប្លន់ម៉ូតូខ្ញុំ ពួកវាសួរថា មានគ្នាប៉ុន្មាននាក់ខ្ញុំថា មាន ០៣នាក់ ពេលនោះអាសក់វែង ដែលមានរូបលេខ ០២ នេះ និយាយខ្សឹបតិចថា ពួកអាអស់ហ្នឹងហើយវាសួរដេញនាងខ្ញុំហាក់ដូចពន្យាពេល អ្នករត់មកសួរខ្ញុំហាក់ដូចជាដឹងថា អ្នកប្លន់ជាអ្នកណា គឺមានឈ្មោះ **គ ភស** រូបទី ១ និងឈ្មោះ **អ គន** រូបទី ២ ។ ភិនភាគអ្នកដែលនាងខ្ញុំបានឃើញពេលប្លន់នាងខ្ញុំនោះ គឺជិះម៉ូតូម៉ាកវីវ៉ា ពាក់អាវពងក្រសា ខោខូវប៊យជើងវែង សក់ស្លួតក្រាស់ និង ច្រមុះស្រួច និង មានពុកមាត់រុយៗ អ្នកជិះកណ្តាលពាក់អាវពណ៌លឿង លាតដៃខ្លីខោចម្ពាជើងវែង សក់រួញតិចៗ កំពស់ ១.៦០ម៉ែត្រជាង មាឌល្មម ចំណែកអ្នកភ្ជង់នាងខ្ញុំ ខ្ញុំមើលមិនទាន់ទេ ពីព្រោះភ័យពេក ។ អ្នកជិះម៉ូតូមកប្លន់នាងខ្ញុំនេះ នាងខ្ញុំមិនដែលស្គាល់ទេពីមុន តែចំណាំមុខបាននៅពេលប្លន់ ក្រោយពេលនាងខ្ញុំ និង បងប្រុសទៅប្តឹងនៅសង្កាត់បានមួយសន្ទុះក៏ប៉ូលីសចាប់ជនល្មើសបាន ពេលនោះប៉ូលីសបណ្តើរជននេះកាត់មុខនាងខ្ញុំ ហើយជនល្មើសនេះក៏បានសួរទៅបងប្រុសនាងខ្ញុំថា បងឯងរកខ្ញុំមានការអ្វីរំពេចនោះបងខ្ញុំថា អត់ទេ ចំណែកអ្វីជននេះសួរតែបងខ្ញុំមិនសួរអ្នកដទៃ ព្រោះនៅទីនោះមានមនុស្សច្រើន ។ ពេលខ្ញុំកំពុងអង្គុយក្នុងទីស្នាក់ការប៉ុស្តិ៍ប៉ូលីសបឹងទំពុន ស្រាប់តែប៉ូលីសបណ្តើរជនល្មើសមួយមកតាំងពីចុះលើឡាននាងខ្ញុំស្គាល់វាច្បាស់ នាងខ្ញុំក៏ស្រែកថា មួយហ្នឹងហើយ ព្រោះការចាប់នេះក្រោយពេលប្លន់មិនដល់មួយម៉ោងផង ។ អ្នកដែលប៉ូលីសបណ្តើរមកនេះនៅពេលប្លន់ម៉ូតូនាងខ្ញុំគេជិះកណ្តាល គឺម្នាក់ដែលមាននៅក្នុងរូបទី ១ របស់ប៉ូលីស ចំណែករូបទី ៤ នាងខ្ញុំមានការសង្ស័យយ៉ាងខ្លាំងថា ជននេះជាអ្នកបើកម៉ូតូប្លន់នាងខ្ញុំ ។ ក្នុងរឿងប្លន់ម៉ូតូរបស់នាងខ្ញុំនេះមានអ្នកឃើញសកម្មភាពនេះ គឺឈ្មោះ **ម** នៅជិតផ្ទះនាងខ្ញុំ ហើយគាត់ឃើញករណីប្លន់នេះ គឺនៅមុខផ្ទះគាត់តែម្តង ក្នុងរឿងនេះនាងខ្ញុំប្តឹងសុំទាមទារម៉ូតូមកវិញក្នុងតម្លៃចំនួន ១.០០០ដុល្លាអាមេរិក និង សុំទាមទារជម្ងឺចិត្តចំនួន ២.០០០ដុល្លាអាមេរិក និង សុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

សាក្សីឈ្មោះ **ស សច** ហៅ **ចរ** ឆ្លើយថា កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោង ៥:០០ល្ងាច ឈ្មោះ **គ ភស** បាននៅមើលគេលេងបៀជាមួយខ្ញុំនៅផ្ទះយាយ **ម** រហូតដល់ម៉ោង ០៧ និង ៣០នាទី គឺមិនបានដើរទៅណាទេ ដូចនេះការចោទប្រកាន់ថា វាប្លន់នោះ គឺជាការមិនត្រឹមត្រូវឡើយ ហើយការចាប់ខ្លួនវានេះ គឺចាប់នៅនឹងផ្ទះរបស់វាតែម្តង ។

សាក្សីឈ្មោះ **ភ ចថទ** កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោង ៤:០០ ឈ្មោះ **ភ សគគ** បានយកឆ្នោតទៅដាក់ឱ្យកូនកញ្ច្រែង ហើយបានមកដល់ផ្ទះនាងខ្ញុំនៅវេលាម៉ោង ០៥ និង ៣០នាទីល្ងាច រួចហើយវាបានងូតទឹក ហើយមើលទូរទស្សន៍អស់រយៈពេល ០៥ នាទី នាងខ្ញុំក៏ប្រើវាឱ្យទៅដូរហ្គាស់ចំនួន ០១កំប៉ុង ព្រោះហ្គាស់ដែលទិញមកនោះដាក់ទៅវាមិនឆេះ ពេលវាជិះម៉ូតូមកផ្ទះខ្ញុំនោះ គឺម៉ូតូម៉ាកសេ ៥០ គុបជ្រុង ពណ៌ទឹកប៊ិច ស្រាប់តែនៅ

វេលាម៉ោង ០៩ និង ៥០នាទីល្ងាច សមត្ថកិច្ចបានចាប់ខ្លួនឈ្មោះ **ភ សគគ** តែម្តង នៅទីរងផ្ទះអ្នកលក់ហ្គាស់ ដែលឈ្មោះ **ភ សគគ** ទៅដូរនោះ ការដែលចាប់ខ្លួនឈ្មោះ **ភ សគគ** នេះ គឺជាការមិនត្រូវឡើយ ។

សាក្សីឈ្មោះ **ឃ ឆ** ( អវត្តមាន ) តាមកំណត់ហេតុ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ មានសកម្មភាពប្លន់ម៉ូតូនៅមុំវត្តសន្សំកុសល ហើយមានមនុស្សនិយាយពីសកម្មភាពប្លន់ ដែលទាក់ទិននៅកន្លែងកើតហេតុ ពេលនោះមានក្មេងម្នាក់បានឆ្លើយប្រាប់ខ្ញុំថា គេប្លន់ម៉ូតូមនុស្សស្រីជិះ ហើយខ្ញុំឈរមើលហេតុការណ៍នៅកន្លែងកើតហេតុមួយសន្ទុះដែរ ។ ខ្ញុំបានឃើញពីចំងាយពេលដែលខ្ញុំជិះម៉ូតូបានឮសំលេងនារីស្រែក ខ្ញុំងាកទៅឃើញមានមនុស្សចុះពីលើម៉ូតូ តែមិនដឹងគេធ្វើអ្វី ។

សាក្សីឈ្មោះ **អ អជរ** ហៅ **ម** ( អវត្តមាន ) វេលាប្រហែល ០៩ល្ងាចជាង ខ្ញុំកំពុងអង្គុយបញ្ចុកបបរកូន ចំងាយពីកន្លែងប្លន់ម៉ូតូមកនាងខ្ញុំប្រហែល ៨០ម៉ែត្រពុំមានអ្វីបាំងពីមុខខ្ញុំទេ សកម្មភាពប្លន់នោះ គឺមានក្មេងស្ទាវចំនួន ០៣នាក់ ជិះម៉ូតូម៉ាកវីវ៉ា ពណ៌ឈាមជ្រូកបានដកកាំភ្លើងភ្ជង់ទៅលើជនរងគ្រោះឈ្មោះ **រ** ដែលជិះម៉ូតូម៉ាកសេ ១០០ ពណ៌ខ្មៅ ជនរងគ្រោះ នាងខ្ញុំស្គាល់ច្បាស់ គឺនៅក្រោយផ្ទះនាងខ្ញុំ ចំពោះជនល្មើសដែលធ្វើសកម្មភាពប្លន់នេះ គឺក្មេង១ សុទ្ធតែមានសក់ត្រង់ៗ១ពុំមានសក់វែងទេ ក្នុងចំណោមមនុស្សទាំង ០៣នាក់ដែលប្លន់នោះ ។ សកម្មភាពប្លន់នោះ នាងខ្ញុំពុំបានឃើញច្បាស់ថា អ្នកណាចុះមកភ្ជង់ទេ តែពេលនោះអ្នកដែលបានមកប្លន់នេះ គឺបើកមកឈប់ពីមុខម៉ូតូរបស់ ជនរងគ្រោះ ហើយអ្នកបើកនេះបានយកដៃឆ្វេងរបស់វាមកមួលហ្គែម៉ូតូរបស់ជនរងគ្រោះកុំឱ្យរលត់ ពេលប្លន់នោះ ជនរងគ្រោះមានបំណងចង់បត់ចូលផ្ទះនាងខ្ញុំតែចូលមិនទាន់ ហើយពេលភ្ជង់ជនរងគ្រោះ គឺភ្ជង់ចំគុម្ពត្រចៀកខាងស្តាំ រួចសំលុតឱ្យជនរងគ្រោះចុះពីលើម៉ូតូរបស់វាមក ហើយឡើងជិះម៉ូតូរបស់ជនរងគ្រោះចេញទៅ ។ ចំពោះរូបថតដែល តុលាការបង្ហាញនាងខ្ញុំនេះ គឺនាងខ្ញុំស្គាល់ជនសក់វែងក្នុងរូបទី ២ នេះច្បាស់ ព្រោះជននេះបានមកសួរជនរងគ្រោះអំពី ភិនភាគម៉ូតូ ហើយជនរងគ្រោះបានសុំឱ្យជនសក់វែងរូបទី២ នេះឱ្យជួយរកម៉ូតូខ្លួនភ្លាមនោះដែរ ជនសក់វែងនេះចេះតែទទូច សួរអំពីជនល្មើសប្លន់ម៉ូតូយកទៅ ។ គឺជននេះបានមកសួរសកម្មភាពប្លន់ ក្រោយពេលប្លន់រួចហើយភ្លាមៗតាមនាងខ្ញុំដឹង ជនសក់វែងនេះ គឺធ្លាប់មានសង្សារនៅជិតនេះ ចំពោះរូបទី ១. ៣. ៤ នាងខ្ញុំពុំស្គាល់ពួកគេទេ គឺនាងខ្ញុំស្គាល់តែរូបទី ២ ប៉ុណ្ណោះ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំង ០៣នាក់ ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយរបស់ ជនរងគ្រោះ ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីរួចមកឃើញ ថា ជនជាប់ចោទពិតជាបានធ្វើសកម្មភាពប្លន់ម៉ូតូរបស់ជនរងគ្រោះប្រាកដមែន តែនៅពេលសវនាការនេះ ជនជាប់ចោទ ទាំង ០៣នាក់ បានឆ្លើយបដិសេធថា ខ្លួនពុំបានធ្វើសកម្មភាពប្លន់ទេនោះ គឺជាការឆ្លើយដោះសារតែប៉ុណ្ណោះ ហើយនៅក្នុង រឿងនេះជនរងគ្រោះបានចង្អុលបង្ហាញយ៉ាងច្បាស់ថា ខ្លួនបានស្គាល់មុខជនល្មើសម្នាក់សក់វែង គឺឈ្មោះ **គ សឈ** ។ ហេតុនេះខ្ញុំតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ទុកជាត្រឹមត្រូវតាមច្បាប់ ហើយសុំឱ្យតុលាការសំរេចសេចក្តី ដោយ ផ្តន្ទាទោសជនល្មើសទាំង ០៣នាក់នេះតាមច្បាប់តទៅ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយរបស់ជនរងគ្រោះ ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី ក្រោយបានស្តាប់ក្រឡាបញ្ជីអានចម្លើយរបស់សាក្សី ក្រោយពីបានស្តាប់សេចក្តី

សន្និដ្ឋានរបស់តំណាងអយ្យការរួចមក ឃើញថា កូនក្តីរបស់ខ្ញុំបាទពុំបានប្រព្រឹត្តអំពើល្មើសដូចការចោទប្រកាន់ឡើយ គឺជនជាប់ចោទទាំង ០៣នាក់ពុំបានធ្វើសកម្មភាពប្លន់ទេ ហើយសមត្ថកិច្ចបានចាប់ខ្លួនកូនក្តីខ្ញុំនៅនឹងផ្ទះផ្សេងៗពីគ្នាមិនមែនចាប់ខ្លួនជាក់ស្តែងនៅនឹងកន្លែងកើតហេតុនោះទេ ហើយការចាប់ខ្លួនកូនក្តីខ្ញុំនេះមកឱ្យជនរងគ្រោះចង្អុលបង្ហាញថា កូនក្តីខ្ញុំបានប្លន់ម៉ូតូរបស់ខ្លួន តែតាមពិតកូនក្តីរបស់ខ្ញុំពុំបានប្រព្រឹត្តរឿងហេតុ ដែលកើតមានមកនេះទាល់តែសោះ ។ ហេតុនេះសុំលោកចៅក្រមមេត្តាលើកលែងចោទប្រកាន់មកលើកូនក្តីខ្ញុំ ហើយសុំដោះលែងកូនក្តីខ្ញុំឱ្យមានសេរីភាពដូចដើមវិញ ចាប់ពីថ្ងៃនេះតទៅដោយក្តីអនុគ្រោះ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ **ក សគគ** ឆ្លើយថា សុំតុលាការមេត្តាដោះលែងខ្ញុំបាទ ឱ្យមានសេរីភាពចាប់ពីថ្ងៃនេះតទៅ ដោយខ្ញុំបាទមិនបានប្រព្រឹត្តអំពើល្មើសដូចការចោទប្រកាន់នេះទេ ។

ជនជាប់ចោទឈ្មោះ **អ គន** ឆ្លើយថា សុំតុលាការមេត្តាដោះលែងខ្ញុំបាទឱ្យមានសេរីភាពដូចដើមវិញ ចាប់ពីថ្ងៃនេះតទៅ ដោយខ្ញុំបាទមិនបានប្រព្រឹត្តអំពើល្មើសដូចការចោទប្រកាន់នេះទេ ។

ជនជាប់ចោទឈ្មោះ **គ ភស** ឆ្លើយថា សុំតុលាការមេត្តាដោះលែងខ្ញុំបាទ ឱ្យមានសេរីភាពចាប់ពីថ្ងៃនេះតទៅ ដោយខ្ញុំបាទមិនបានប្រព្រឹត្តអំពើល្មើសដូចការចោទប្រកាន់នេះទេ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយរបស់ជនរងគ្រោះ
-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយសាក្សី
-ក្រោយពីបានពិនិត្យឯកសារភស្តុតាង
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

## តុលាការក្រុងភ្នំពេញ

-ក្រោយពីបានពិនិត្យ ពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-គ្មានភស្តុតាងដាក់បន្ទុកដល់ជនជាប់ចោទទាំង ០៣នាក់នេះទេ ដោយតុលាការបានធ្វើការផ្ទៀងផ្ទាត់ចម្លើយសាក្សី ចម្លើយជនជាប់ចោទទាំង ០៣នាក់ និង ផ្ទៀងផ្ទាត់ចម្លើយរបស់ជនជាប់ចោទពេលសវនាការហាក់ដូចជា គ្មានមូលដ្ឋានច្បាស់លាស់ថា ជនជាប់ចោទបានប្រព្រឹត្តបទល្មើសប្លន់ម៉ូតូនោះទេ ព្រោះថាកាលដែលសមត្ថកិច្ចបានធ្វើការចាប់ និង ឃាត់ខ្លួនពួកគេ គឺជនជាប់ចោទទាំង ០៣នាក់ពុំបានធ្វើសកម្មភាពប្លន់ បានន័យថា ការចាប់ និង ឃាត់ខ្លួនរបស់សមត្ថកិច្ចប៉ូលីស គឺចាប់ និង ឃាត់ខ្លួន ពុំមែនជាបទល្មើសជាក់ស្តែងនោះទេ ។

-លោកមេធាវីការពារជនជាប់ចោទទាំង ០៣នាក់ បានលើកឡើងអំពីផ្លូវច្បាប់ ដោយបញ្ជាក់អំពីអង្គហេតុ និង បញ្ជាក់អំពីអង្គច្បាប់ មានលក្ខណៈសមហេតុផល គប្បីតុលាការយកមកធ្វើជាមូលដ្ឋានក្នុងការសំរេចសេចក្តីបាន ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាន តម្កល់ការចោទប្រកាន់ទុកជាបានការ ថ្វីត្បិតតែជនជាប់ចោទទាំង ០៣នាក់បានឆ្លើយបដិសេធយ៉ាងណាក៏ដោយ ព្រោះថា ជនរងគ្រោះថែមទាំងបានចង្អុលបង្ហាញអំពីជនល្មើសថែមទៀត ។ តុលាការគិតថា ចំណុចសន្និដ្ឋានរបស់តំណាងអយ្យការបានព្យាយាមសាកសួរដេញដោលដល់ជនជាប់ចោទ ទាំង ០៣នាក់ ពេលសវនាការយ៉ាងយកចិត្តទុកដាក់បំផុត តុលាការឃើញថា ជនជាប់ចោទនៅតែប្រកែក ថាខ្លួនពិតជាពុំបានប្រព្រឹត្តដដែល ។

-ការចង្អុលបង្ហាញរបស់ជនរងគ្រោះ គឺជាការរៀបចំរបស់ប៉ូលីស ដែលចាប់ឃាត់ខ្លួនជនសង្ស័យទាំងនេះមកចង្អុលបង្ហាញឱ្យជនរងគ្រោះឆ្លើយដាក់ ពុំមែនជនរងគ្រោះចង្អុលបង្ហាញក្នុងពេលដែលប្រព្រឹត្តបទល្មើសទេ តុលាការគិតថា ដោយសារជនរងគ្រោះមានការសោកស្ដាយម៉ូតូ អាចជាអំពើរបស់ជនដទៃផ្សេងពីជនជាប់សង្ស័យទាំង ០៣នាក់ ជនរងគ្រោះអាចឆ្លើយទាំងបំពានក៏អាចថាបាន ម្យ៉ាងទៀតផ្អែកតាមចម្លើយសាក្សីឈ្មោះ **អ អជរ** ហៅ ម. បានបំភ្លឺតាមកំណត់ហេតុសាកសួររបស់ចៅក្រមស៊ើបអង្កេតថា ជនដែលប្លន់ម៉ូតូថ្ងៃកើតហេតុ គឺសុទ្ធតែមានសក់ក្បាលត្រងិលៗទេ ។ ដោយការផ្ទៀងផ្ទាត់លើគ្រប់ភស្តុតាងទៅ តុលាការឃើញមានភាពច្របូកច្របល់នាពេលសវនាការនេះពុំអាចដាក់បន្ទុកទៅលើជនជាប់ចោទទាំង ០៣នាក់នេះទេ ម្យ៉ាងការឃុំខ្លួនក៏ហួសនូវការកំណត់ផងដែរ តុលាការពុំអាចផ្ដន្ទាទោសជនជាប់សង្ស័យដោយភាពស្រពិចស្រពិល ពុំច្បាស់លាស់នោះបានឡើយ ។

-តាមស្មារតីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា **វិមតិសង្ស័យត្រូវផ្ដល់ប្រយោជន៍ដល់ជនជាប់ចោទ** ។

-ជនជាប់ចោទទាំង ០៣នាក់ បានបដិសេធថា ខ្លួនពុំបានប្លន់ម៉ូតូទេ ទាំងនៅអយ្យការ ទាំងនៅចៅក្រមស៊ើបអង្កេត និង ទាំងនាពេលសវនាការនេះ ដែលគប្បីតុលាការពិចារណា ។

## <u>សេចក្ដីសម្រេចតុលាការ</u>

១-សំរេចឱ្យរួចផុតពីការចោទប្រកាន់លើជនជាប់ចោទឈ្មោះ :

-**ភ សគគ** ហៅ **ភី** ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ *របររកស៊ីកម្មករឆ្នោត* កើតនៅភូមិអណ្ដូង ស្រុកដង្កោ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិសន្សំកុសលទី ១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ **ភ ខ** ( ស ) ម្ដាយឈ្មោះ **ណា ម** ( រ ) នៅលីវ ទោសពីមុន *គ្មាន* ។

-**អ គន** ហៅ ម អាយុ ២០ឆ្នាំ ភេទប្រុស ជាតិខ្មែរ កើតនៅភូមិស្ទឹង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នភូមិព្រៃកទាល់ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ **អ មល** ( រ ) ម្ដាយឈ្មោះ **ស សរ** នៅលីវ ទោសពីមុន *គ្មាន* ។

-**គ ភស** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ *របររកស៊ីនៅផ្ទះ* កើតនៅខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ន ភូមិសន្សំកុសលទី ១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ **គ ស** ( រ ) ម្ដាយឈ្មោះ **ន ឈល** ( រ ) នៅលីវ ទោសពីមុន *គ្មាន* ។

ពីបទប្លន់ទ្រព្យសម្បត្តិប្រជាជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋជាស្ថាពរ ចាប់ពីថ្ងៃប្រកាសសាលក្រមតទៅ ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ

កំបាំងមុខជនរងគ្រោះ សំរេចបើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**ចាត្តលេខា និង ត្រា**

[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

*ភ្នំពេញ.ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៣*

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជំរះ**

[redacted]